00906117

E267/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 05 / 2013
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូរ ឧត្តរ**

កាលបរិច្ឆេទ: ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

**សេចក្តីសម្រេចលើសំណើសុំកោះហៅសាជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 និងសុំឲ្យពិនិត្យឡើងវិញលើបែបបទ ពាក់ព័ន្ធនឹងសក្ខីកម្មស្តីពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសំណើ និងចម្លើយតបនានាដែលពាក់ព័ន្ធ (E240, E240/1, E250, E250/1, E267, E267/1 និង E267/2)**

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Jacques VERGÈS
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម

1. បន្ទាប់ពីការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូបនៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ និងថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ រួចមក អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើសុំពាក់ព័ន្ធគ្នាចំនួនពីរ ដែលស្នើសុំឱ្យពិនិត្យឡើងវិញចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះបដិសេធការកោះហៅសាជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 (ថៅ នី) និងបញ្ជាក់អំពីបែបបទនៃការសួរសំណួរដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការ និងជាពិសេសការកំណត់វិសាលភាពនៃសក្ខីកម្មស្តីពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី[1]។ ភាគីផ្សេងទៀតបានដាក់ចម្លើយតបទៅនឹងសំណើទាំងពីរនៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ និងនៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២[2]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើបន្ថែមទៀតរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៩២ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដែលលើកឡើងថាអង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការវាយតម្លៃទៅលើតម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្រោមបទដ្ឋានតែមួយដូចគ្នានឹងសក្ខីកម្មដែលបានផ្តល់ដោយសាក្សីដូច្នោះដែរ ហើយមិនត្រូវផ្តល់ទម្ងន់ទាបជាង ដោយសារតែសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើងដោយមិនបានធ្វើសម្បថនោះឡើយ[3]។ មេធាវីការពារក្តីរបស់ ខៀវ សំផន និង អៀង សារី បានឆ្លើយតបទៅនឹងសំណើនេះនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣[4]។

---

[1] សំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីដើម្បីកំណត់អំពីវិសាលភាពនៃសក្ខីកម្មស្តីពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់សំណើសុំ ឯកសារ E240 ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១២ ("សំណើរបស់សហមេធាវីនាំមុខ")។ សំណើសុំឱ្យពិនិត្យឡើងវិញនូវសេចក្តីសម្រេចបដិសេធការកោះហៅសាជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 និងសុំឱ្យកែប្រែបែបបទក្នុងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E250 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ ("សំណើរបស់ ខៀវ សំផន")។

[2] ចម្លើយតបទៅនឹង "សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីកំណត់វិសាលភាពនៃការថ្លែងទុក្ខសោក របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ" ឯកសារ E240/1 ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("ចម្លើយតបរបស់ ខៀវ សំផន")។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់ ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញនូវសេចក្តីសម្រេចមិនកោះហៅឡើងវិញដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 និងសុំឱ្យកែប្រែនីតិវិធីក្នុងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី" ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ E250/1 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")។

[3] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៩២ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E267 ("សេចក្តីសន្និដ្ឋានស្របតាមវិធាន ៩២") កថាខណ្ឌ ៥, ២២-២៣។

[4] ចម្លើយតបទៅនឹងសារណារបស់សហព្រះរាជអាជ្ញាទាក់ទងនឹងតម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ E267/1។ ចម្លើយតបរបស់ អៀង សារី ទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៩២ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ E267/2។

## ២. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ នៅពេលបញ្ចប់ការផ្តល់សក្ខីកម្មនៅក្នុងសវនាការ ដើមបណ្តឹងរដ្ឋប្បវេណី TCCP-169 (យឹម សុវណ្ណ) ត្រូវបានផ្តល់ឱកាសឱ្យធ្វើការថ្លែងអំពីទុក្ខសោករបស់អ្នកស្រីក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ មុនពេលស្តាប់នូវការថ្លែងទុក្ខសោករបស់អ្នកស្រី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំទៅក្រុមនៃអង្គជំនុំជម្រះដោយផ្ទាល់មាត់ថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវបានអនុញ្ញាតឱ្យថ្លែងអំពីព្យសនកម្មដែលបានទទួលរងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល[5]។ ដោយពិចារណាលើលក្ខណៈទូទៅនៃសំណើនេះ អង្គជំនុំជម្រះសាលាដំបូងបានស្នើដល់សហមេធាវីនាំមុខឱ្យធ្វើការបង្ហាញពីជំហររបស់ពួកគេជាលាយលក្ខណ៍អក្សរ។ សហមេធាវីនាំមុខបានបង្ហាញជំហររបស់ ខ្លួននៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២[6]។

3. ក្នុងអំឡុងសវនាការថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យអ្នកស្រី យឹម សុវណ្ណ ថ្លែងអំពីទុក្ខសោកទាំងអស់ដែលអ្នកស្រីបានជួបប្រទះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះបានផ្តល់ឱកាសឱ្យគ្រប់ភាគីទាំងអស់ឆ្លើយតប ទៅនឹងផ្នែកនៃសេចក្តីថ្លែងដែលភាគីមានបំណងជំទាស់នៅពេលបញ្ចប់ការថ្លែងអំពីទុក្ខសោករបស់អ្នកស្រី និងបានចង្អុលបង្ហាញបន្ថែមទៀតថា ការអនុវត្តនេះនឹងត្រូវបន្តរហូតដល់មានការជូនដំណឹងបន្ថែមទៀត[7]។ នៅក្នុងអំឡុងពេលនៃការថ្លែងទុក្ខសោក ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានយោងទៅលើបទពិសោធន៍របស់ខ្លួនក្នុងការធ្វើពលកម្មដោយបង្ខំ បន្ទាប់ពីគាត់ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ និងការសម្លាប់ក្រុមគ្រួសាររបស់គាត់ក្នុងឆ្នាំ ១៩៧៨[8]។ នៅពេលនោះ មេធាវីការពារក្តីមិនបានជំទាស់ទៅនឹងផ្នែកនៃការថ្លែងអំពីទុក្ខសោកទាំងនេះរបស់អ្នកស្រីឡើយ[9]។

4. នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 (ចៅ នី) បានស្នើសុំការអនុញ្ញាតដើម្បីសួរជនជាប់ចោទ ខៀវ សំផន ពាក់ព័ន្ធនឹងស្ថានភាពនៃការបាត់ខ្លួនឪពុកមារបស់គាត់ បន្ទាប់ពីមានលិខិតមួយបញ្ជូនមកពីជនជាប់ចោទនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដែលក្នុងលិខិតនោះបាន

---

[5] ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ 2 (ភាសាអង់គ្លេស)។

[6] ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ 17។ សូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ 2-16 (ចម្លើយតបរបស់ក្រុមមេធាវីការពារក្តីទាំងអស់) និងសំណើរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២-៣។

[7] ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ 17-18 ។

[8] ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ 19-20 ។

[9] ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ 22-25 ។

ទទួចឱ្យឪពុកមារបស់ដើមបណ្តឹងរដ្ឋប្បវេណីវិលត្រលប់មកទីក្រុងភ្នំពេញ[10]។ មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅនឹងសំណើនេះ[11]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់ ចៅ នី ក្នុងការសួរជនជាប់ចោទដោយផ្ទាល់ ប៉ុន្តែបានអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីសួរជនជាប់ចោទ តាមរយៈប្រធានអង្គជំនុំជម្រះសាលាដំបូង។ ជនជាប់ចោទបានបញ្ជាក់ថា គាត់មិនចង់ឆ្លើយតបទៅនឹងសំណួរណាមួយនៅក្នុងដំណាក់កាលនេះទេ ប៉ុន្តែគាត់អាចឆ្លើយតបទៅនឹងសំណួរនៅពេលបញ្ចប់ការបង្ហាញភស្តុតាងទាំងអស់[12]។ សំណើរបស់មេធាវីការពារក្តី ខៀវ សំផន ស្នើសុំសួរសំណួរទៅលោក ចៅ នី បន្ថែមទៀត ត្រូវបានអង្គជំនុំជម្រះ បដិសេធដោយផ្អែកលើមូលដ្ឋានថា ជនជាប់ចោទបានអនុវត្តសិទ្ធិរបស់គាត់នៅស្ងៀម មិនឆ្លើយតបទៅលើបញ្ហានេះ[13]។ ជនជាប់ចោទ ខៀវ សំផន បានស្នើសុំឱ្យពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ព្រមទាំងការពិនិត្យជាទូទៅឡើងវិញលើបែបបទក្នុងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី[14]។

## ៣. **សារណា**

### ៣.១ **ការកំណត់វិសាលភាពនៃការថ្លែងអំពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី**

5. សហមេធាវីនាំមុខលើកឡើងថា សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងពីការឈឺចាប់ដែលខ្លួនទទួលរង គឺជាសិទ្ធិដែលមិនអាចកាត់ផ្តាច់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយសិទ្ធិនេះអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញពីការប៉ះពាល់មកលើខ្លួនចំពោះបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់[15]។ ការឈឺចាប់គឺជាលទ្ធផលនៃការប៉ះទង្គិចផ្លូវចិត្តត្រួតៗលើគ្នា និងមិនអាចត្រូវបានបែងចែកជាផ្នែកៗ និងជ្រើសរើសពាក់ព័ន្ធតែទៅលើឧក្រិដ្ឋកម្មទាំងឡាយ ដែលបង្កើតជាផ្នែកនៃសំណុំរឿង ០០២/០១ បានឡើយ។ ដូច្នេះ វាមិនចាំបាច់ និងមិនអាចទៅរួចឡើយ ក្នុងការតម្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីថ្លែងតែអំពីព្យសនកម្មដែលពួកគាត់បានទទួលរងដោយសារឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១[16]។ លើសពីនេះទៀត ការថ្លែងអំពីការឈឺចាប់ដោយដើមបណ្តឹងរដ្ឋប្បវេណីមិនបង្កើតបានជាភស្តុតាង

---

[10] ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ 95 ។

[11] ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ 91-92 ។

[12] ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ 94, 98 ។

[13] ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ 105 ។

[14] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ២៥។

[15] សំណើរបស់សហមេធាវីនាំមុខ កថាខណ្ឌ ១០។

[16] សំណើរបស់សហមេធាវីនាំមុខ កថាខណ្ឌ១២-១៤។ ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ 4-6 ។

ដែលប៉ះពាល់ដល់ជនជាប់ចោទឡើយ ហើយឥទ្ធិពលនៃការថ្លែងទាំងនេះត្រូវបានកម្រិតត្រឹមតែអាចឱ្យអង្គជំនុំជម្រះធ្វើការវាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មប៉ុណ្ណោះ។ ការថ្លែងពីការឈឺចាប់នេះក៏អាចអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញនូវទុក្ខសោក និងក្តីឈឺចាប់ក្នុងនាមជនរងគ្រោះទាំងអស់ផងដែរ ដែលអាចរួមចំណែកដល់យុត្តិធម៌ និងការផ្សះផ្សាជាតិ[17]។ ហេតុដូច្នេះ សហមេធាវីនាំមុខស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសថា នៅពេលបញ្ចប់ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីអាចថ្លែងពាក់ព័ន្ធនឹងទុក្ខសោកវេទនាទាំងអស់ដែលពួកគាត់បានជួបប្រទះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យតែម្តង[18]។ សហមេធាវីនាំមុខបានស្នើបន្ថែមទៀតដល់អង្គជំនុំជម្រះសាលាដំបូងកុំអនុញ្ញាតឱ្យមានការធ្វើអត្ថាធិប្បាយរបស់ភាគីដទៃទៀតនៅក្នុងសវនាការពាក់ព័ន្ធនឹងសេចក្តីថ្លែងអំពីការឈឺចាប់ទាំងនេះ ឬយ៉ាងហោចណាស់ អង្គជំនុំជម្រះបង្គាប់ថា ការធ្វើអត្ថាធិប្បាយទាំងនេះអាចធ្វើទៅបានតែបន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការប៉ុណ្ណោះ ដើម្បីទប់ស្កាត់ការធ្វើអត្ថាធិប្បាយដែលអាចប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬធ្វើឱ្យមានសម្ពាធផ្លូវចិត្តលើពួកគាត់[19]។ សហព្រះរាជអាជ្ញាយល់ស្របថា ការបែងចែកការឈឺចាប់រវាងសំណុំរឿង ០០២/០១ និងផ្នែកដែលនៅសេសសល់នៃសំណុំរឿង ០០២ មានលក្ខណៈសិប្បនិម្មិត ជាពិសេសនៅពេលដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានចាត់ទុកថា អាចទទួលយកបានដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះសំណុំរឿង ០០២ ទាំងមូល។ សហព្រះរាជអាជ្ញាកត់សម្គាល់ទៀតថា គោលបំណងនៃការថ្លែងអំពីទុក្ខសោកទាំងនេះ ត្រូវបានកម្រិតត្រឹមផលប៉ះពាល់ដល់ជនរងគ្រោះប៉ុណ្ណោះ ដូច្នេះមិនចាំបាច់កំណត់វិសាលភាពនៃការថ្លែងអំពីទុក្ខសោកទាំងនេះឡើយ[20]។

6. ជាការឆ្លើយតប មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា អង្គហេតុដែលអ្នកស្រី យឹម សុវណ្ណ បានប្រើប្រាស់សម្រាប់រៀបរាប់អំពីព្យសនកម្មលើខ្លួន ស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះក្តីនេះយ៉ាងច្បាស់[21]។ ក្នុងការពិពណ៌នាអំពីព្យសនកម្មនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់អំពីអង្គហេតុដែលមិនមានការអនុញ្ញាតដែលមិនពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ហើយទាក់ទិននឹងអង្គហេតុទាំងនេះ ជនជាប់ចោទ ពុំមានឱកាសក្នុងការការពារខ្លួនឡើយ[22]។ ទោះបីជាមានការទទួលស្គាល់ថា ការឈឺចាប់ផ្លូវចិត្ត

---

[17] សំណើរបស់សហមេធាវីនាំមុខ កថាខណ្ឌ ១៦, ១៨-២០។

[18] សំណើរបស់សហមេធាវីនាំមុខ កថាខណ្ឌ ១៥។

[19] សំណើរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២២-២៥។

[20] ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ 6-8។

[21] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៥។

[22] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១៦។ ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ 11 ។

ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងអាចត្រួតៗលើគ្នា ដែលពិបាកក្នុងការបំបែកចេញជាផ្នែកៗ ក៏ដោយ ក៏វាមិនមែនជាព្យសនកម្មពិតប្រាកដលើរាងកាយ ដែលពិតជាលទ្ធផលនៃព្រឹត្តការណ៍ជាក់លាក់នោះឡើយ[23]។ មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា មិនត្រូវអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសក្ខីកម្មអំពីបញ្ហានានាដែលមិនមែនជាផ្នែកនៃសំណុំរឿង ០០២/០១ ឡើយ ពីព្រោះអង្គហេតុទាំងនេះនឹងមិនត្រូវបានយកមកពិភាក្សា ឬសួរដេញដោលឡើយ ដូច្នេះវាមិនមានប្រយោជន៍អ្វីក្រៅពីធ្វើឱ្យប៉ះពាល់ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីនោះទេ[24]។ ទោះបីជាមានការយល់ស្របថា ការជំនុំជម្រះដ៏ត្រឹមត្រូវ និងប្រកបដោយយុត្តិធម៌ អាចមានឥទ្ធិពលទៅលើការផ្សះផ្សាជាតិក៏ដោយ ក៏ការផ្សះផ្សាជាតិនេះមិនអាចត្រូវយកមកប្រើជាលេសមួយដើម្បីរំលោភបំពានលើគោលការណ៍ជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ជាមូលដ្ឋាននោះដែរ[25]។ មេធាវីការពារក្តីស្នើឱ្យអង្គជំនុំជម្រះបដិសេធសំណើ និងបង្គាប់ឱ្យភាគីទាំងអស់គោរពព្រំដែនកំណត់ដែលជាលទ្ធផលចេញមកពីការបំបែកកិច្ចដំណើរការនីតិវិធី ដូចដែលអង្គជំនុំជម្រះបានបង្គាប់នោះ ដោយផ្អែកលើមូលដ្ឋានថា ព្រំដែនកំណត់ទាំងនេះនឹងត្រូវបានពិចារណាឡើងវិញ ប្រសិនបើអង្គជំនុំ-ជម្រះយល់ស្របតាមសំណើរបស់សហមេធាវីនាំមុខ[26]។ មេធាវីការពារក្តីរបស់ អៀង សារី យល់ស្របថា ការឈឺចាប់ដែលកើតចេញមកពីឧក្រិដ្ឋកម្មទាំងឡាយក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ គឺមិនមានការពាក់ព័ន្ធឡើយ[27]។

7. ទោះបីជាមេធាវីការពារក្តី នួន ជា ទទួលស្គាល់ថា ការបំបែកនូវការទទួលរងការឈឺចាប់ជាផ្នែកៗ គឺជាការលំបាកក៏ដោយ ក៏មេធាវីកត់សម្គាល់ថា មេធាវីការពារក្តីជួបប្រទះនឹងបញ្ហាប្រឈមដូចគ្នាក្នុងការកំហិតវិសាលភាពលើអង្គហេតុទាំងនោះដែលខ្លួនយល់ឃើញថាពាក់ព័ន្ធ ក្រោយពីមានដីកាបំបែកកិច្ចដំណើរការនីតិវិធី[28]។ ហេតុដូច្នេះ មេធាវីការពារក្តី នួន ជា លើកឡើងថា "ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីនេះត្រូវបានផ្តល់ឱ្យឱកាសដើម្បីនិយាយរៀបរាប់អំពីអ្វីៗទាំងអស់ ដែលគាត់ជួបប្រទះនោះ នោះ

---

[23] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១៧ ។

[24] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ២០ ។

[25] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ២២។

[26] ចម្លើយតបរបស់ ខៀវ សំផន ទំព័រ ៥។ ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ 11-13។ សូមមើល ផងដែរ ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E124 និងសេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5 ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២។

[27] ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ១៥។

[28] ប្រតិចារឹក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ទំព័រ ៩-១០។

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh
National Road 4 ,Chaom Chau , Dangkao, Phnom Penh, Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941 Web: www.eccc.gov.kh

យើងខ្ញុំ ស្នើថា កូនក្តីរបស់ខ្ញុំ [ជនជាប់ចោទ] គប្បីតែបានផ្តល់ឱកាសដូចដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីទទួលបានដែរ ដើម្បីឲ្យមានសមភាពក្នុងការថ្លែងនេះ”[29]។

## ៣.២. សំណើសុំកោះហៅសាក្សីដែលមានលេខសម្គាល់ TCCP-187 និងការផ្លាស់ប្តូរលំដាប់លំដោយនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

8. មេធាវីការពារក្តី ខៀវ សំផន ស្នើសុំឲ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ថៅ នី (TCCP-187) ដើម្បីអាចឲ្យមេធាវីការពារក្តី សួរដេញដោលគាត់អំពីការចោទប្រកាន់ដែលធ្វើឡើងប្រឆាំងនឹងជនជាប់ចោទក្នុងអំឡុងពេលនៃការថ្លែងអំពីទុក្ខសោករបស់គាត់[30]។ មេធាវីការពារក្តីចោទប្រកាន់ថា ទោះបីជាជនជាប់ចោទបានជ្រើសយកការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប ក៏សិទ្ធិរបស់ជនជាប់ចោទត្រូវបានរំលោភបំពានផងដែរ[31]។ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាប់ទាក់ទងដោយផ្ទាល់ទៅនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ។ ការសួរដេញដោលនេះមិនអាចត្រូវបានប្រមើលមើលទុកដោយមេធាវីការពារក្តីពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលជំនុំជម្រះ ឬទម្រង់បែបបទព័ត៌មានជនរងគ្រោះ ហើយមេធាវីការពារក្តីមិនត្រូវបានផ្តល់ឱកាសឲ្យសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីអំពីការចោទប្រកាន់ថ្មីទាំងនេះនោះទេ[32]។ មេធាវីការពារក្តី ខៀវ សំផន ក៏បានស្នើសុំឲ្យធ្វើការកែប្រែលំដាប់លំដោយនៃការសួរសំណួរដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីអាចឲ្យមេធាវីការពារក្តីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីនៅពេលបញ្ចប់សក្ខីកម្មរបស់ខ្លួន ដោយរួមទាំងបញ្ហាពាក់ព័ន្ធនឹងការថ្លែងអំពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី[33]។ ការអនុញ្ញាតឲ្យមេធាវីការពារក្តីផ្តល់មតិយោបល់ទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រោយពេលដែលដើមបណ្តឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ ដូចការស្នើសុំរបស់សហមេធាវីនាំមុខនោះ មិនមានលក្ខណៈស្របគ្នានឹងប្រភេទនៃការសួរដេញដោលនៃកិច្ចដំណើរការនីតិវិធីនេះទេ[34]។ ជាជម្រើសផ្សេងមួយទៀត ហើយប្រសិនបើអង្គជំនុំជម្រះមិនយល់ព្រមកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ថៅ នី នោះទេ មេធាវីការពារក្តីស្នើសុំឲ្យប្រកាសថា សេចក្តីថ្លែងអំពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺមិនអាចទទួលយកជាភស្តុតាងបានទេ អនុលោមតាមវិធាន ៨៧(២) នៃ

---

[29] ប្រតិចារិក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ទំព័រ១០។

[30] សំណើសុំរបស់ ខៀវ សំផន កថាខណ្ឌ១, ៩។

[31] សំណើសុំរបស់ ខៀវ សំផន កថាខណ្ឌ៣-១៧។

[32] សំណើសុំរបស់ ខៀវ សំផន កថាខណ្ឌ១០-១៣។

[33] សំណើសុំរបស់ ខៀវ សំផន កថាខណ្ឌ១៨-២៥។

[34] សំណើសុំរបស់ ខៀវ សំផន កថាខណ្ឌ១៥។

វិធានផ្ទៃក្នុង ដោយតាមវិធាននេះ អង្គជំនុំជម្រះអាចចេញសេចក្តីសម្រេចនានាដោយពឹងផ្អែកតែទៅលើភ័ស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងត្រូវមានការសួរដេញដោលតែប៉ុណ្ណោះ[35]។

9. សហព្រះរាជអាជ្ញាគាំទ្រសំណើសុំឱ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ថៅ នី ដោយផ្អែកលើមូលដ្ឋានថា ព័ត៌មានដែលមាននៅក្នុងការថ្លែងអំពីទុក្ខសោករបស់គាត់ តម្រូវឱ្យមានការសួរដេញដោលដោយភាគីនានា និងដើម្បីជាផលប្រយោជន៍យុត្តិធម៌[36]។ ទោះបីជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាប្រឆាំងនឹងសំណើសុំឱ្យកែប្រែលំដាប់លំដោយនៃការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើមូលដ្ឋានថា មិនចាំបាច់ធ្វើដូច្នេះទេ ក្នុងការការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌នោះ[37]។ លំដាប់លំដោយនៃការសួរដេញដោលបច្ចុប្បន្ននេះ ស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់ប្រធានអង្គជំនុំជម្រះ ដើម្បីសម្រេចលើបញ្ហាទាំងនេះផ្អែកតាមវិធានផ្ទៃក្នុង[38]។ អង្គជំនុំជម្រះសាលាដំបូងត្រូវអនុញ្ញាតឱ្យភាគីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីបន្ថែម នៅពេលដែលការថ្លែងអំពីទុក្ខសោកបានក្លាយជាបញ្ហា ដល់ភាគីណាមួយ ឬភាគីផ្សេងៗជឿថា ការថ្លែងទាំងនោះត្រូវមានការសាកសួរបន្ថែមទៀត ប៉ុន្តែសហព្រះរាជអាជ្ញាលើកឡើងថា មិនមានការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទនៅក្នុងរឿងក្តីនេះទេ[39]។

10. សហមេធាវីនាំមុខបានទំនាក់ទំនងជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ ដោយបានលើកឡើងថា សហមេធាវីនាំមុខមិនបានបដិសេធមិនឱ្យកោះហៅ ថៅ នី នោះទេ ដរាបណាវិសាលភាពនៃការសួរដេញដោលរបស់មេធាវីការពារក្តី ខៀវ សំផន ត្រូវបានកម្រិតត្រឹមបញ្ហានានាដែលបានលើកឡើងនៅក្នុងសេចក្តីថ្លែងអំពីទុក្ខសោករបស់ ថៅ នី ដែលពាក់ព័ន្ធនឹងឪពុកមារបស់គាត់ដែលបានទទួលមរណភាពនោះ[40]។

## ៣.៣. តម្លៃ និងទម្ងន់ជាភ័ស្តុតាងនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

11. ឆ្លើយតបទៅនឹងការពិភាក្សានៅក្នុងសវនាការកាលពីថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៣ ទាក់ទងនឹងទម្ងន់ដែលត្រូវផ្តល់ឱ្យចំពោះសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញាបានដាក់សេចក្តី

---

[35] សំណើសុំរបស់ ខៀវ សំផន កថាខណ្ឌ១៦។

[36] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣។

[37] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៤។

[38] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៦។

[39] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៥, ៨។

[40] អ៊ីម៉ែលរបស់សហមេធាវីនាំមុខផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២។

សន្និដ្ឋានអនុលោមតាមវិធាន ៨២ ដោយស្នើសុំឱ្យធ្វើការប្រកាសថា ទម្ងន់ និងតម្លៃជាភ័ស្តុតាងនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី គួរតែត្រូវបានវាយតម្លៃផ្អែកតាមករណីនីមួយៗ នៅពេលបញ្ចប់ការជំនុំជម្រះ និងមិនត្រូវផ្តល់ទម្ងន់ និងតម្លៃទាបជាង ដោយសារតែសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើងដោយមិនបានធ្វើសម្បថនោះឡើយ[41]។

12. ជាការឆ្លើយតប មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា វាជាការខុសឆ្គងក្នុងការអះអាងថា មិនមានភាពខុសគ្នាពិតប្រាកដរវាងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងសាក្សីនោះ[42]។ ទោះបីជាមេធាវីការពារក្តី ខៀវ សំផន មិនជំទាស់ទៅនឹងការលើកឡើងថា ទម្ងន់នៃភ័ស្តុតាងដែលត្រូវផ្តល់ឱ្យទៅសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី គួរតែត្រូវវាយតម្លៃទៅតាមករណីនីមួយៗ ដោយគិតអំពីភាពអាចជឿជាក់បាននៃសក្ខីកម្មនោះ ក៏មេធាវីការពារក្តី ខៀវ សំផន ពិតជាជំទាស់នឹងការមិនបែងចែកភាពខុសគ្នារវាងភាគីផ្សេងៗនៃកិច្ចដំណើរការនីតិវិធី និង "ការអនុវត្តបទដ្ឋានដូចគ្នា តាមរបៀបដូចគ្នា ចំពោះសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី"[43]។

## ៤. សំអាងហេតុ

### ៤.១. ក្របខណ្ឌគតិយុត្ត

13. ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក អាចឱ្យជនរងគ្រោះចូលរួមជាភាគីនៅក្នុងដំណើរការជំនុំជម្រះក្តីព្រហ្មទណ្ឌលើជនជាប់ចោទ ដើម្បីគាំទ្រសហព្រះរាជអាជ្ញា និងដើម្បីទាមទារសំណងផ្លូវចិត្ត និងជាសមូហភាព ចំពោះព្យសនកម្មដែលបង្កឡើងដោយផ្ទាល់ពីឧក្រិដ្ឋកម្មនានា ដែលជនជាប់ចោទ

---

[41] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៨២ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារE267 ("សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ១-២, ១៣, ១៤, ២០-២៣ (យោងទៅលើសញ្ញាណក្នុងការដាក់ទោស មានអធិកភាពនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលបារាំង ដែលប្រព័ន្ធច្បាប់ស៊ីវិលកម្ពុជាយកជាមូលដ្ឋាន ដែលតម្រូវឱ្យចៅក្រមជំនុំជម្រះធ្វើការវាយតម្លៃលើភ័ស្តុតាងដោយឯករាជ្យ និងឈានទៅធ្វើសេចក្តីសម្រេច)។

[42] "ចម្លើយតបទៅនឹងសារណារបស់សហព្រះរាជអាជ្ញាទាក់ទងនឹងតម្លៃជាភ័ស្តុតាងនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី" ឯកសារ E267/1 ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣ ("ចម្លើយតបទៅនឹងសារណាអនុលោមតាមវិធាន៨២") កថាខណ្ឌ២-៣ (លើកឡើងថាសហព្រះរាជអាជ្ញាធ្វើឱ្យមានភាពច្របូកច្របល់ ទាក់ទងនឹងតួនាទីរបស់ភាគីផ្សេងៗគ្នានៃកិច្ចដំណើរការនីតិវិធី តាមរយៈការច្របល់តួនាទីសាក្សី ជាមួយនឹងតួនាទីដើមបណ្តឹងរដ្ឋប្បវេណី។ *សូមមើលផងដែរ* "ចម្លើយតបរបស់ អៀង សារី ទៅនឹងសារណារបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី" ឯកសារE267/2 ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ (ក្នុងចំណោមចំណុចផ្សេងៗទៀត បានលើកឡើងថា សក្ខីកម្មដែលមិនបានធ្វើសម្បថ គួរត្រូវបានផ្តល់នូវទម្ងន់ និងតម្លៃជាភ័ស្តុតាងទាបជាងសក្ខីកម្មដែលបានធ្វើសម្បថ)។

[43] ចម្លើយតបទៅនឹងសារណាអនុលោមតាមវិធាន៨២ កថាខណ្ឌ១៥-១៦។

ត្រូវបានរកឃើញថាមានពិរុទ្ធភាព[44]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងផ្តល់ឱកាសឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីថ្លែងទាក់ទងនឹងការឈឺចាប់របស់ខ្លួន និងអនុញ្ញាតឱ្យចោទជាសំណួរទៅជនជាប់ចោទតាមរយៈប្រធានអង្គជំនុំជម្រះ ទាំងនៅក្នុងសំណុំរឿង០០១ និងសំណុំរឿង០០២/០១[45]។ ការធ្វើបែបនេះគឺស្របតាមកាតព្វកិច្ចដ៏សំខាន់បំផុតរបស់អង្គជំនុំជម្រះក្នុងការធានាភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី។

## ៤.២. វិសាលភាពត្រឹមត្រូវនៃសេចក្តីថ្លែងអំពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី និងទម្រង់បែបបទនៃការសួរដេញដោល

14. ទោះបីជាក្នុងការអនុវត្ត អង្គជំនុំជម្រះអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញអំពីការឈឺចាប់របស់ខ្លួនក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យជាទូទៅក៏ដោយ ក៏អង្គជំនុំជម្រះបានរំឭកដល់ភាគីនានាអំពីវិសាលភាពមានកំណត់នៃសក្ខីកម្មទាំងអស់ ក្រោយពីការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២[46]។ អង្គជំនុំជម្រះសាលាដំបូងបានញែកគ្រប់ពេលវេលារវាងសក្ខីកម្មលើអង្គហេតុនានា ដែលត្រូវបានកំណត់ក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និងត្រូវមានការសួរតទល់គ្នាជាមួយនឹងសេចក្តីថ្លែងអំពីទុក្ខសោកជាទូទៅ ដែលដើមបណ្តឹងរដ្ឋប្បវេណីអាចលើកឡើងដោយសេរីនៅចុងបញ្ចប់នៃសក្ខីកម្មរបស់ខ្លួន[47]។

15. នៅក្នុងសេចក្តីថ្លែងរបស់ពួកគាត់អំពីទុក្ខវេទនា អង្គជំនុំជម្រះសាលាដំបូងពុំបានតម្រូវជាទូទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីបែងចែករវាងព្យសនកម្មដែលបានទទួលរងដោយសារតែអង្គហេតុនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និងព្យសនកម្មជារួមដែលបានទទួលរងក្នុងអំឡុងសម័យកាលកម្ពុជាប្រជាធិប

---

[44] *កាំង ហ្គេកអ៊ាវ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារE188 ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៦៦០។

[45] ប្រតិចារឹក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ទំព័រ៦០។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ (CHAU Ny) ទំព័រ៩៤-៩៥, ១០៤ និងវិធាន ៩០(២) នៃវិធានផ្ទៃក្នុង ("គ្រប់សំណួរទាំងអស់អាចសួរទៅបានដោយមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះសាលាដំបូង។ លើកលែងតែការសាកសួររបស់សហព្រះរាជអាជ្ញា និងមេធាវី រាល់សំណួរទាំងអស់ត្រូវធ្វើតាមរយៈប្រធានអង្គជំនុំជម្រះ និងតាមលំដាប់លំដោយដែលបានកំណត់ដោយប្រធាន")។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣២៥(២) ("ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងៗទៀត ត្រូវសួរតាមរយៈប្រធានសវនាការ")។

[46] ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះអនុញ្ញាតឱ្យមានសក្ខីកម្ម ដោយរួមបញ្ចូលសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីគ្របដណ្តប់បញ្ហាដែលនៅក្រៅពីវិសាលភាពនៃសំណុំរឿង ០០២/០១ នៅពេលដែលកាលៈទេសៈពិសេស ត្រូវបានលើកឡើង៖ *សូមមើល ឧទា.* ប្រតិចារឹក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ (យឹង សុវណ្ណ) ទំព័រ១៧-១៨។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ (ជុំ សុខា) ទំព័រ ៦១-៦២។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ទំព័រ៥៣, ៦១។ ប្រតិចារឹក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ទំព័រ ១០៨។ ប្រតិចារឹក ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១១ (រម៉ាន យុន Roman Yun) ទំព័រ៥០។

[47] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ទំព័រ ២៧-២៨។

តែយ្យឡើយ ដែលយ៉ាងហោចណាស់នៅពេលដែលវាពុំបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ផ្ទុយនឹងអ្វីដែលមេធាវីការពារក្តី នួន ជា បានលើកនៅក្នុងបរិបទនេះ ដើមបណ្តឹងរដ្ឋប្បវេណីពុំដែលត្រូវបានផ្តល់ឱ្យឡើយនូវ "ឱកាសដើម្បីលើកឡើងអំពីអ្វីៗដែលបានកើតឡើងចំពោះពួកគាត់" ឡើយ លើកលែងតែសេចក្តីថ្លែងអំពីទុក្ខវេទនាជាទូទៅរបស់ពួកគាត់ សក្ខីកម្មរបស់ពួកគាត់ត្រូវបានកំហិតត្រឹមអង្គហេតុនានាពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ តែប៉ុណ្ណោះ។

16. ការអនុវត្តបែបនេះត្រូវបានធ្វើឡើងជាប្រចាំនៅក្នុងសំណុំរឿង ០០២[48]។ ការអនុវត្តនេះត្រូវបានមេធាវីការពារក្តីជំទាស់ជាលើកដំបូងនៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់ យឹម សុវណ្ណ។ តបទៅនឹងសក្ខីកម្មនោះ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ បន្តកិច្ចដំណើរការនីតិវិធីជាមួយនឹងការថ្លែងអំពីទុក្ខវេទនារបស់គាត់ ប៉ុន្តែបានផ្តល់ឱកាសទៅភាគីដើម្បីជំទាស់ទៅនឹងផ្នែកនានានៃការថ្លែងដែលពួកគាត់យល់ថាប៉ះពាល់ប្រយោជន៍របស់ជនជាប់ចោទ[49]។

17. ជាទូទៅ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការអនុវត្តនេះមិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ឡើយ។ ទីមួយ វាគ្រាន់តែជាការថ្លែងអំពីទុក្ខវេទនាដែលមិនស្ថិតនៅក្រោមការកម្រិតដោយដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចនានាដែលពាក់ព័ន្ធ។ ប្រសិនបើមានការចោទប្រកាន់ថាសិទ្ធិរបស់ជនជាប់ចោទត្រូវបានរំលោភបំពាននោះ មេធាវីការពារក្តីទទួលបានឱកាសគ្រប់គ្រាន់ក្នុងការជំទាស់តវ៉ា។ ទីពីរ ដើម្បីជាផលប្រយោជន៍នៃភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងក៏បានតម្រូវឱ្យសហមេធាវីនាំមុខធ្វើការធានា

---

[48] ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (ក្លាន រ៉ុត) ទំព័រ 87-88 (ភាសាអង់គ្លេស) (ដែលចង្អុលបង្ហាញថា អង្គជំនុំជម្រះបានផ្តល់ឱកាសឱ្យ ក្លាន រ៉ុត "ជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីថ្លែងនូវទុក្ខសោក និងព្យសនកម្មនានាដែល [គាត់] បានទទួលរងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ")។ សូមមើល ផងដែរ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (អែម អឿន) ទំព័រ 28 (ភាសាអង់គ្លេស)។ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីថ្លែងអំពីការឈឺចាប់ និងទុក្ខសោកក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ និងប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ 74 (ភាសាអង់គ្លេស)។

[49] ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ 2, 8-16 (យឹម សុវណ្ណ)។ ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ទំព័រ ១០៥។ ប្រតិចារឹក ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ 4-5។ ប្រតិចារឹក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ទំព័រ 87 និងថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ 86-87។ ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ 21 និង (ចៅ នី) ទំព័រ 41, 91។ ប្រតិចារឹក ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ 36។ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ 9, 74។ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២ (គីម វ៉ាន់ឌី) ទំព័រ 79។ ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២ (គីម វ៉ាន់ឌី) ទំព័រ 27។ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONCO) ទំព័រ 103។

ផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានស្នើឱ្យផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ពាក់ព័ន្ធតែទៅនឹងបញ្ហានានាក្នុងសំណុំរឿង ០០២/០១ ប៉ុណ្ណោះ[50]។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់បន្ថែមទៀតឱ្យសហមេធាវីនាំមុខ ជួយដើមបណ្តឹងរដ្ឋប្បវេណីក្នុងការរៀបចំសេចក្តីថ្លែងអំពីទុក្ខសោករបស់ពួកគាត់ ដើម្បីរារាំងការចោទប្រកាន់ថ្មីៗដែលប្រឆាំងនឹងជនជាប់ចោទនៅដំណាក់កាលនោះ[51]។ ដូច្នេះ មានការការពារគ្រប់គ្រាន់ ដើម្បីធានាបាននូវការគោរពយ៉ាងពេញលេញចំពោះសិទ្ធិរបស់ជនជាប់ចោទ។

18. អង្គជំនុំជម្រះសម្រេចថាពុំចាំបាច់ពិនិត្យមើលឡើងវិញអំពីការអនុវត្តរបស់ខ្លួន ក្នុងការអនុញ្ញាតឱ្យថ្លែងអំពីទុក្ខវេទនាទាក់ទងនឹងសម័យកាលកម្ពុជាប្រជាធិបតេយ្យទាំងមូល ឬកែប្រែលំដាប់លំដោយនាពេលបច្ចុប្បន្ននៃការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ យ៉ាងណាក៏ដោយ ដើម្បីជាផលប្រយោជន៍នៃភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះទទួចសុំឱ្យសហមេធាវីនាំមុខធានាបានថា សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងអង្គហេតុនានា ត្រូវបានកំហិតត្រឹមបញ្ហាដែលកំពុងផ្តោតបច្ចុប្បន្ននៅក្នុងសំណុំរឿង ០០២/០១ និងធានាថា សេចក្តីថ្លែងអំពីទុក្ខវេទនារបស់ពួកគាត់ បើទោះបីជាពុំត្រូវបានកំហិតដូច្នេះក៏ដោយ ក៏ត្រូវបានកំហិតត្រឹមគោលបំណងដែលសេចក្តីថ្លែងអំពីទុក្ខវេទនាទាំងនោះប្រាថ្នាចង់បាន។ មេធាវីការពារក្តីនឹងបន្តទទួលបានឱកាសដើម្បីធ្វើសេចក្តីអត្ថាធិប្បាយ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីបានចាកចេញពីបន្ទប់សវនាការ[52]។

## ៤.៣. ការរំលោភដែលត្រូវបានចោទប្រកាន់នៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ និងសំណើសុំកោះហៅឡើងវិញចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-187

19. អង្គជំនុំជម្រះសាលាដំបូងឯកភាពជាមួយមេធាវីការពារក្តី ខៀវ សំផន ដែលថាសេចក្តីថ្លែងរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីទុក្ខវេទនា ពុំអាចក្លាយជាលេសក្នុងការបង្ហាញអង្គហេតុថ្មី ឬធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទ ដោយពុំបានឆ្លងកាត់ការលើកទឡ្ហីករណ៍តទល់ឡើយ។ នៅពេលដែលការថ្លែងរបស់

---

[50] ការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E141 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២, ៤។

[51] ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ទំព័រ 106។ ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ទំព័រ 23-24។

[52] ប្រតិចារឹក ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ទំព័រ 70។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ទំព័រ 39។ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ទំព័រ 77។ ប្រតិចារឹក ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ទំព័រ 29។ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONCO) ទំព័រ 107។

ដើមបណ្តឹងរដ្ឋប្បវេណីអំពីទុក្ខវេទនា បង្ហាញអំពីការចោទប្រកាន់លើអង្គហេតុថ្មីៗ ពិសេសប្រសិនបើត្រូវបានចាត់ទុកថាជាការដាក់បន្ទុកទៅជនជាប់ចោទ ឱកាសដើម្បីជំទាស់តទល់ទាក់ទងនឹងការចោទប្រកាន់ទាំងនោះ នឹងត្រូវបានផ្តល់ទៅឲ្យមេធាវីការពារក្តី និងអាចតម្រូវឲ្យមានការកោះហៅដើមបណ្តឹងរដ្ឋប្បវេណីជាថ្មីសម្រាប់ការសួរដេញដោលបន្ថែមទៀត។ អង្គជំនុំជម្រះសាលាដំបូងឯកភាពផងដែរជាមួយមេធាវីការពារក្តីដែលថា ការចោទប្រកាន់ទាំងនោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទៅលើជនជាប់ចោទកាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ តាមរយៈទម្រង់ព័ត៌មានជនរងគ្រោះ ឬមធ្យោបាយអ្វីផ្សេងពីនេះមិនត្រូវបានរំពឹងទុកជាមុនឡើយ[53]។

20. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថាជាផលប្រយោជន៍នៃយុត្តិធម៌ក្នុងការកោះហៅ ចៅ នី ជាថ្មី ប៉ុន្តែកំហិតការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ត្រឹមតែការរំឭកអំពីផ្នែកទាំងឡាយនៃការថ្លែងអំពីទុក្ខវេទនារបស់គាត់ ដែលជនជាប់ចោទពុំទាន់មានឱកាសដើម្បីឆ្លើយតបប៉ុណ្ណោះ។

## <u>៤.៤. តម្លៃជាភស្តុតាង និងទម្ងន់នៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី</u>

21. នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីមិនចាំបាច់ធ្វើសម្បថ ប៉ុន្តែ “អាចផ្តល់សក្ខីកម្ម និងដាក់សេចក្តីថ្លែងការណ៍របស់ពួកគាត់ នៅចំពោះមុខអង្គជំនុំជម្រះ និងវាយតម្លៃជាភស្តុតាង ត្រង់ ចំណុចពាក់ព័ន្ធ និងមានតម្លៃជាភស្តុតាង” និងបានទទួលស្គាល់លក្ខណៈពិសេសនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅសវនាការ[54]។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ឃើញទៀតថា បើទោះបីជាមានភាពខុសគ្នាផ្នែកគោលគំនិតនៅក្នុងសំណៅជាភាសាផ្សេងៗនៃវិធាន ៨៧(១) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏អង្គជំនុំជម្រះ “បានប្រកាន់យកវិធីសាស្ត្ររួមមួយដែលបានវាយតម្លៃនៅក្នុងគ្រប់កាលៈទេសៈទាំងអស់អំពីភាពគ្រប់គ្រាន់នៃភស្តុតាង” ហើយ “តាមការវាយតម្លៃដែលមានសំអាងហេតុអំពីភស្តុតាង ការសង្ស័យណាមួយអំពីពិរុទ្ធភាព ត្រូវបានបកស្រាយជាប្រយោជន៍របស់ជនជាប់

[53] ឯកសារ D22/253 (ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ) ផ្នែក “ខ” (“ព័ត៌មានទាក់ទងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់”)។ សូមមើល ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ 95។

[54] *កាំង ហ្គេកអ៊ាវ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ឯកសារ E188, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៥២-៥៣ (ដោយបានកត់សម្គាល់ទៀតថា “ក្របខណ្ឌច្បាប់ អ.វ.ត.ក បែងចែករវាងអ្នកនៅរស់រានមានជីវិត [នៅ ស២១ និង ស២៤] ដែលផ្តល់សក្ខីកម្មជាសាក្សី និងអ្នកនៅរស់រានមានជីវិតដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងដែលបានផ្តល់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះផងដែរ។ អនុលោមតាមវិធាន ២៣(៦) នៃវិធានផ្ទៃក្នុង ជនរងគ្រោះនឹងក្លាយជាភាគីនៃដំណើរការនីតិវិធីនៅពេលជនរងគ្រោះបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ហេតុដូច្នេះ អ្នកនៅរស់រានមានជីវិតមិនអាចត្រូវគេស្តាប់យកចម្លើយក្នុងឋានៈជាសាក្សីបានទេ ហើយត្រូវបានលើកលែងដោយវិធានផ្ទៃក្នុងចេញពីលក្ខខណ្ឌតម្រូវនៃការធ្វើសក្ខីកម្មក្រោមសម្បថស្របតាមសាសនា ឬជំនឿ”)។

ចោទ"[55]។ នៅក្នុងសាលក្រមនៃសំណុំរឿង ០០១ អង្គជំនុំជម្រះបានប្រើប្រាស់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី ដើម្បីគាំទ្រការសម្រេចមួយចំនួនទៅតាមការសមស្រប។

22. អង្គជំនុំជម្រះសាលាដំបូងសូមគូសបញ្ជាក់ថា នៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះនឹងអនុវត្តតាមវិធីសាស្ត្រដូចគ្នានៅក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនដើម្បីថ្លឹងថ្លែងដោយឯករាជ្យ និងសមស្របអំពីភស្តុតាងទាំងអស់ដែលត្រូវបានបង្ហាញ និងដើម្បីការពារភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ ហេតុដូច្នេះ ទម្ងន់ដែលត្រូវផ្ដល់ទៅឱ្យសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នឹងត្រូវបានវាយតម្លៃទៅតាមករណីនីមួយៗ ដោយពិនិត្យទៅលើភាពអាចជឿជាក់បាននៃសក្ខីកម្មនោះ។ ដោយហេតុថាសហព្រះរាជអាជ្ញាពុំបានសំណូមពរអ្វីមួយជាក់លាក់នៅដំណាក់កាលនេះ អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាអំពីការលើកឡើងខាងលើរបស់ភាគីនៅក្នុងសាលក្រម។

**ហេតុដូច្នេះ ផ្អែកតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**ឯកភាព** តាមសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលស្នើសុំអនុញ្ញាតឱ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការថ្លែងអំពីទុក្ខវេទនាទាក់ទងនឹងសម័យកាលកម្ពុជាប្រជាធិបតេយ្យទាំងមូល។

**បញ្ជាក់ថា** អង្គជំនុំជម្រះនឹងបន្តលំដាប់លំដោយបច្ចុប្បន្ននៃការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី និងការអនុវត្តរបស់ខ្លួន ក្នុងការអនុញ្ញាតឱ្យមេធាវីការពារក្ដីធ្វើសេចក្ដីអត្ថាធិប្បាយស្ដីពីការថ្លែងអំពីទុក្ខវេទនាបន្ទាប់ពីដើមបណ្ដឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ ប៉ុន្តែអង្គជំនុំជម្រះណែនាំឱ្យសហមេធាវីនាំមុខរៀបចំការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងលក្ខណៈមួយដែលបែងចែករវាងសក្ខីកម្មលើអង្គហេតុ និងសេចក្ដីថ្លែងទាក់ទងនឹងទុក្ខវេទនា និង

**ឯកភាព** តាមសំណើរបស់ ខៀវ សំផន ដែលស្នើសុំកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី ថៅ នី (ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម (TCCP-187) ជាថ្មី ទៅតាមកាលបរិច្ឆេទ និងពេលវេលា ដែលនឹងត្រូវជូនដំណឹងនៅពេលក្រោយ ទាក់ទងនឹងការចោទប្រកាន់ថ្មីៗដែលត្រូវបានធ្វើប្រឆាំងនឹងជនជាប់ចោទ ខៀវ សំផន ក្នុងអំឡុងពេលនៃការថ្លែងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះអំពីទុក្ខវេទនារបស់គាត់។

**ប្រកាសថា** នៅពេលវាយតម្លៃអំពីភស្តុតាងនៅក្នុងសាលក្រម ទម្ងន់ដែលត្រូវផ្ដល់ទៅឱ្យសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នឹងត្រូវបានវាយតម្លៃទៅតាមករណីនីមួយៗ ដោយពិនិត្យទៅលើភាពអាចជឿជាក់បាន

[55] *កាំង ហ្កេកអ៊ាវ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ឯកសារ E188, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៥៥។

នៃសក្ខីកម្មនោះ ហើយបន្ទាប់ពីការវាយតម្លៃដែលមានសំអាងហេតុអំពីភស្តុតាងនេះ វិមតិសង្ស័យអំពីពិរុទ្ធភាពនឹងត្រូវបកស្រាយជាប្រយោជន៍ដល់ជនជាប់ចោទ។

ភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣

ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល ណុន